អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ការបង់ពន្ធជូនរដ្ឋគឺជាកាតព្វកិច្ច របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប
ដើម្បីចូលរួមចំណែកការពារ និង ការអភិវឌ្ឍន៍មាតុភូមិកម្ពុជា

To Pay Tax Is The Obligation For All Cambodian People And
To Contribute To The Defense And Development Of Our Nation!




# ភាគព្វកិច្ចសារពើពន្ធ
# និង
# ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែក
# របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

បទបង្ហាញដោយ

**អគ្គនាយកដ្ឋានពន្ធដារ**

២២ ធ្នូ ២០២០

# មាតិកា

**១.ទិដ្ឋភាពទូទៅ**

១.១. គោលបំណង និងគោលដៅ

១.២. និយមន័យ

**២. ការលើកលែងពន្ធលើប្រាក់ចំណូល**

២.១.ប្រាក់ចំណូលលើកលែងពន្ធ

២.២.ប្រាក់ចំណូលមិនជាប់ពន្ធ

**៣.កាតព្វកិច្ចសារពើពន្ធ**

២.១. ចុះបញ្ជីពន្ធដារ

២.២. ការប្រកាសបង់ពន្ធ

**៤. ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែក**

# ១. និដ្ឋភាពទូទៅ

# ១.១. គោលបំណង និងគោលដៅ

- គោលបំណងពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- គោលដៅផ្តល់ការណែនាំបន្ថែមអំពីកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបន្តធានាការអនុវត្តប្រកបដោយ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

# ១.២. និយមន័យ

- **សមាគម** សំដៅដល់អង្គការសមាជិកភាព ឬអង្គការដែលមានលក្ខណៈ ប្រហាក់ប្រហែល ដែលត្រូវបង្កើតឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួនដោយមិនទាញយកចំណេញ ឬមិនយកកម្រៃចែកគ្នា។ សមាគមរួមបញ្ចូលផងដែរ សភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម។ សមាគមដែលក្នុងប្រទេសកម្ពុជាហៅថា **សមាគមក្នុងស្រុក** រីឯសមាគមបង្កើតឡើងនៅក្រៅប្រទេស ហៅថា **សមាគមបរទេស**។
- អង្គការមិនមែនរដ្ឋាភិបាល សំដៅដល់អង្គការមិនមែនសមាជិកភាព ឬអង្គការដែលមានលក្ខណៈប្រហាក់ប្រហែល រួមទាំងមូលនិធិដែលត្រូវបានបង្កើតឡើង ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលក្រៅពីស្ថាប័នរដ្ឋាភិបាល ក្នុងគោលបំណងផ្ដល់មូលនិធិ ឬសេវាកម្មលើវិស័យមួយ ឬច្រើនដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃចែកគ្នា។ អង្គការមិនមែនរដ្ឋាភិបាលដែលក្នុងប្រទេសកម្ពុជាហៅថា**អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក** រីឯអង្គការមិនមែនរដ្ឋាភិ-បាលដែលបង្កើតឡើងនៅក្រៅប្រទេស ហៅថា **អង្គការមិនមែនរដ្ឋាភិបាលបរទេស**។

# ១.២. និយមន័យ

- **សកម្មភាពគោលដៅសុទ្ធសាធ ៖**

១.អង្គការមិនមែនរដ្ឋាភិបាល សំដៅដល់សកម្មភាព ដែលត្រូវបានរៀបចំឡើង និងដំណើការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រអប់រំ ហើយគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។

២.សមាគម សំដៅដល់សកម្មភាពរបស់សមាគម ដែលប្រាក់ចំណូលមិនត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល។

- **សកម្មភាពមិនស្ថិតគោលដៅសុទ្ធសាធ** សំដៅដល់សកម្មភាពអាជីវកម្មដោយឡែករបស់អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ដើម្បីស្វែងរកប្រាក់ចំណេញ ឬមូលនិធិ ក្រៅពីសកម្មភាពគោលដៅសុទ្ធសាធ។




# ២. ការលើកលែងពន្ធលើប្រាក់ចំណូល

# ២.១. ប្រាក់ចំណូលលើកលែងពន្ធ

- ប្រាក់ចំណូល ដែលបានត្រូវរៀបចំឡើង និងដំណើរការសម្រាប់សកម្មភាពគោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រអប់រំ ហើយគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។ ចំណូលទាំងនោះរួមមាន មូលនិធិឬអំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល ធនធាននិងទ្រព្យសម្បត្តិរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាល ភាគទានឬវិភាគទានឬបរិវិសទានរបស់សមាជិក និងចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត វៀរលែងតែ ចំណូលពីសកម្មភាពអាជីវកម្មដោយឡែក។
- ប្រាក់ចំណូលមិនជាប់ពន្ធ ដូចមានក្នុងមាត្រា៩ថ្មី នៃច្បាប់ស្ដីពីសារពើពន្ធ

# ២.២. ការទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល

- ដាក់ពាក្យស្នើសុំលើកលែងពន្ធលើប្រាក់ចំណូលមកអគ្គនាយកដ្ឋាន
- ឯកសារភ្ជាប់
  - លក្ខន្តិកៈ និងលិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃ (អង្គការ សមាគមក្នុងស្រុក)
  - អនុស្សរណៈជាមួយក្រសួងការបរទេសននិងសហប្រតិបត្តិការអន្តរជាតិ
  - ត្រូវជូនដំណឹងមកអគ្គនាយកដ្ឋានពន្ធដាររាល់ការផ្លាស់ប្តូរនានា

# ២.៣. ប្រាក់ចំណូលមិនជាប់ពន្ធ

- ប្រាក់ចំណូលដែលជាប់ពន្ធលើប្រាក់បៀវត្ស ឬជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម ។
- ប្រាក់ចំណូលដែលជាថ្លៃឈ្នួលផ្ទះ និងដី របស់បុគ្គលដែលមិនស្ថិតក្នុងរបបស្វ័យប្រកាស។ **ប៉ុន្តែ បុគ្គលជាប់ពន្ធតាមរបបស្វ័យប្រកាសប្រាក់ចំណូលនេះ ជាចំណូលជាប់ពន្ធ។**
- ប្រាក់ចំណូលដែលបានមកពីការលក់ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ផលិតបានដោយខ្លួនឯង។
- ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល លើកលែងតែស្ថាប័នណាដែលធ្វើអាជីវកម្មរកចំណូលដូចជាសហគ្រាសសាធារណៈជាដើម។

# ២.៣. ប្រាក់ចំណូលមិនជាប់ពន្ធ(ត)

▪ ប្រាក់ចំណូលរបស់អង្គការណាមួយដែល÷

ក- ត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធ ខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ អប់រំ។

ខ- គ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

▪ ប្រាក់ចំណូលរបស់អង្គការពលករឬសភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម ក្នុងករណីដែលប្រាក់ចំណូល របស់អង្គការទាំងនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬ រូបវន្តបុគ្គល ។

▪ ភាគលាភ ដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា២០ថ្មី មាត្រា២៣ថ្មី និងមាត្រា២៦ថ្មី នៃច្បាប់នេះត្រូវបានបង់រួចរាល់។




# ៣. កាតព្វកិច្ចសារពើពន្ធ របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

# ៣.១. ការចុះបញ្ជីពន្ធដារ

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវមានកាតព្វកិច្ចចុះបញ្ជីសារពើពន្ធ ក្នុងកំឡុងពេល **១៥** ថ្ងៃ ÷

១. ក្រោយពីចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច

២. ក្រោយមានការផ្លាស់ប្តូរសកម្មភាពអាជីវកម្ម អាស័យដ្ឋាន សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស។

សកម្មភាពសេដ្ឋកិច្ច មានន័យថា ការធ្វើសកម្មភាពរបស់ខ្លួន ទោះបីស្វែងរកប្រាក់ចំណេញក្តី ឬមិនស្វែងរកប្រាក់ចំណេញក្តី។

# ៣.២. ការប្រកាសបង់ពន្ធ

- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពគោលដៅសុទ្ធសាធ ត្រូវដាក់លិខិតប្រកាស÷

  ១. បង់ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ប្រចាំខែ

  ២. ដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពមិនស្ថិតក្នុងគោលដៅសុទ្ធសាធ ត្រូវដាក់លិខិតប្រកាសបង់ពន្ធតាមច្បាប់ស្តីពីសារពើពន្ធ ដែលរួមមាន ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម និងពន្ធ អាករដទៃទៀត។

# ៤.ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែក
# របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

# ១. ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ

➢ *មាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ*




*“បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង ១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។”*

*“ត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងកំឡុង ១៥ថ្ងៃ ក្រោយពីផ្លាស់ប្តូរ អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស។”*



រដ្ឋបាលសារពើពន្ធ

## ១. ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ

- *មាត្រា ៣ (ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ*

“**នីតិបុគ្គល**” សំដៅដល់សហគ្រាស ឬអង្គការនានា ដែលប្រកបអាជីវកម្មទោះបីជាបានឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។ ពាក្យ “នីតិបុគ្គល” រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរក ចំណេញ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ “នីតិបុគ្គល” សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅ ព្រះរាជាណាចក្រកម្ពុជា។ ពាក្យ “នីតិបុគ្គល” ពុំរាប់បញ្ចូលទេនូវក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល។

- *ប្រកាសលេខ ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ*

“**សកម្មភាពសេដ្ឋកិច្ច**” សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើ ជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរក ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

“**អាជីវកម្ម**” សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលពីការ ផលិតនិងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួលឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត។

# ១. ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ

➢ *សេចក្តីណែនាំលេខ ៣០៣៣ អពដ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ ស្តីពីការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល*

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទាំងឡាយណាដែលមានសកម្មភាពអាជីវកម្មដោយឡែក មិនស្ថិតក្នុងគោលដៅសុទ្ធសាទរបស់ខ្លួន ត្រូវ÷

1. ចុះបញ្ជីពន្ធដារ ដាច់ដោយឡែកមួយទៀត នៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ ថ្ងៃក្រោយពីមានសកម្មភាពជីវកម្ម នឹងត្រូវចាត់ទុកថាជាសហគ្រាសឯកបុគ្គល
2. តាមកម្រិតផលរបរ និងប្រភេទអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ស្របតាមប្រកាសលេខ ០២៥ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
3. បង់ពន្ធប៉ាតង់ស្របតាមប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៨របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់។

# ១. ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ

➢ *ប្រកាស០២៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស*

- **អ្នកជាប់ពន្ធតូច** គឺជាសហគ្រាសឯកបុគ្គល មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ៧០០លានរៀល (62,500 $ - 175,000$)
  ឬមានផលរប ឬរំពឹងថាមានផលរប ក្នុងរយៈពេល បី ខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០លានរៀល (ប្រមាណ 15,000$) ឡើងទៅ
- **អ្នកជាប់ពន្ធមធ្យម** គឺជាសហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី ៧០០លានរៀលដល់ ៤ ០០០លានរៀល (175,000$-1,000,000$)
- **អ្នកជាប់ពន្ធធំ** គឺជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៤ ០០០លានរៀល ឡើងទៅ (1,000,000$)

# ១. ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ

- *មាត្រា ១០៣ នៃច្បាប់ស្តីពីសារពើពន្ធ*

  “រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី ហើយពុំបានចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី”

- *មាត្រា ១២៨ និង មាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ*

  ការខកខានមិនបានមកចុះបញ្ជីពន្ធដារតាមកាលកំណត់ត្រូវបានចាត់ទុកថាបានប្រព្រឹត្តិអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលនឹងត្រូវទទួលរងនូវការផាកពិន័យ ឱ្យបង់ពន្ធបន្ថែមចំពោះការប្រព្រឹត្តិអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារជាប្រាក់ចំនួន ២លានរៀលគត់។

- *មាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ*

  ដោយមិនគិតនូវទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានប្រព្រឹត្តិអំពើរាំងស្ទះបទប្បញ្ញត្តិស្តីពីពន្ធដារដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ ពី ៥ លានរៀល ដល់ ១០ លានរៀល ឬជាប់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ ឬទោសទាំងពីរនេះ។

# ២. ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយឡែក

សំណុំឯកសារភ្ជាប់ទាំងអស់ដែលជាច្បាប់ថតចម្លងដែលតម្រូវឱ្យភ្ជាប់ សម្រាប់ការចុះបញ្ជីពន្ធដារ ត្រូវមានការបញ្ជាក់ "ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" ពីមន្ត្រីពន្ធដារមានសមត្ថកិច្ច ឬពីក្រសួង ស្ថាប័នពាក់ព័ន្ធ

- **សម្រាប់អ្នកជាប់ពន្ធតូច**

| ឯកសារតម្រូវ | |
|---|---|
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់ S01) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៣ | រូបថតបច្ចុប្បន្នមិនលើស ០៣ខែ ទំហំ៣៥ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខទទួលខុសត្រូវដោយប្រធាន ឬ អ្នកតំណាងសមាគម ឬអង្គការនានា |
| ៤ | ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម |
| ឯកសារត្រូវភ្ជាប់បន្ថែម បើមាន÷ | |
| ១ | លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ២ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៣ | អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច |

# ២. ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយឡែក

- **សម្រាប់អ្នកជាប់ពន្ធមធ្យម-ធំ**

| **ឯកសារតម្រូវ** | |
|---|---|
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់ ១០១) |
| ២ | លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬ/និង |
| ៣ | លក្ខន្តិកៈរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាល |
| ៤ | ព័ត៌មានគណនីធនាគារសម្រាប់សកម្មភាពអាជីវកម្មដោយឡែក ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារឬសៀវភៅធនាគារ ដែលចេញដោយធនាគារ |
| ៥ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៧ | រូបថតបច្ចុប្បន្នមិនលើស ០៣ខែ ទំហំ៣៥x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខទទួលខុសត្រូវដោយប្រធាន ឬអ្នកតំណាងសមាគម ឬអង្គការនានា |
| ៨ | ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម |
| ៩ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |

# ២. ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយខ្មែរ

➢ បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងដាក់ពាក្យស្នើសុំនៅរដ្ឋបាលសារពើពន្ធ÷

ទម្រង់ 101 (អ្នកជាប់ពន្ធមធ្យម-ធំ)




ទម្រង់ S01 (អ្នកជាប់ពន្ធតូច)



www.tax.gov.kh ឬ

ការិយាល័យចុះបញ្ជីពន្ធដារ

# ២. ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយឡែក

➢ ការពិនិត្យពាក្យស្នើសុំ បញ្ចូលព័ត៌មានបឋម

÷

- ផ្ដល់បាកូដ និងបញ្ចូលព័ត៌មានបឋម, ឈ្មោះសហគ្រាស, ព័ត៌មានទំនាក់ទំនង, អាសយដ្ឋាន, សកម្មភាពអាជីវកម្ម

2017069606




- ការបង់ប្រាក់ពន្ធ និងកម្រៃសេវា

| លរ | បរិយាយ | តូច (៛) | មធ្យម (៛) | ធំ (៛) |
|---|---|---|---|---|
| ១ | ពន្ធប៉ាតង់ | 400,000 | 1,200,000 | 3,000,000 |
| ២ | ពន្ធប្រថាប់ត្រា | - | - | - |
| ៣ | កម្រៃសេវា | 20,000 | 400,000 | 400,000 |
| | សរុប | 420,000 | 1,600,000 | 3,400,000 |

# ២. ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយខ្សែក

- ➢ ថតរូប និងស្នែនម្រាមដៃប្រធានក្រុមប្រឹក្សាភិបាល ឬអ្នកតំណាង ០១រូប។
- ➢ អ្នកជាប់ពន្ធអាចថតរូប និងស្នែនម្រាមដៃ÷
  - ការិយាល័យចុះបញ្ជីពន្ធដារ
  - សាខាពន្ធដារខេត្តសៀមរាប
  - សាខាពន្ធដារខេត្តបាត់ដំបង
  - សាខាពន្ធដារខេត្តកំពង់ចាម
  - សាខាពន្ធដារខេត្តព្រះសីហនុ
  - បញ្ជូរនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា






## ២. ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយឡែក

- ➢ រដ្ឋបាលសារពើពន្ធត្រូវពិនិត្យផ្ទៀងផ្ទាត់ការបំពេញពាក្យសុំចុះបញ្ជី និងការបង់ប្រាក់ពន្ធជាមួយនឹងសំណុំឯកសារភ្ជាប់។ ហើយធ្វើការឆ្លើយតបការស្នើសុំចុះបញ្ជីក្នុងរយៈពេលពី ០៧ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ

- ➢ ឯកសារផ្លូវការសម្រាប់ការចុះបញ្ជី÷
  - វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ អតប
  - ប័ណ្ណពន្ធប៉ាតង់
  - លិខិតជូនដំណឹង
  - ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ



# ២. ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយខ្សែក

- ការចុះប្រគល់ដល់ទីតាំង ដែលស្ថិតនៅរាជធានីភ្នំពេញ ដើម្បីកត់ត្រា GPS និងរូបភាពទីតាំង








កត់ត្រា GPS និងរូបភាពទីតាំង

# ២. ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយឡែក

កំណត់សម្គាល់បន្ថែម÷

- **ឯកសារភ្ជាប់** ដែលជាច្បាប់ថតចម្លង ត្រូវថតម្លងជាឯកសារច្បាប់ដើម ដោយរក្សានូវទម្រង់ និង ទំហំដើម ដោយមិនពង្រីក ឬបង្រួមទំហំឯកសារឱ្យធំ ឬតូច ហួសកម្រិតដែលមិនអាចមើលបាន។ ករណី ឯកសារច្បាប់ដើមដែលមានទំហំធំជាងទំហំក្រដាស A4 ត្រូវថតចម្លងឯកសារនោះក្នុងក្រដាស A4 ដោយបង្រួមទៅតាមភាពជាក់ស្តែង។
- **ការប្រើប្រាស់ទីតាំងទីស្នាក់ការអាជីវកម្មដ្ឋាន** សម្រាប់គោលដៅនៃការចុះបញ្ជីពន្ធដារ អាសយដ្ឋាននៃទីតាំងសហគ្រាស ឬអាជីវកម្មដ្ឋានដែលគ្មានអាគារ (ដីទំនេរ) ឬមានសំណង់ទើបតែចាប់ផ្តើមសាងសង់ មិនអាចប្រើប្រាស់បានមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាអាសយដ្ឋានសម្រាប់ចុះបញ្ជីពន្ធដារ បានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយដ្ឋានពន្ធដារ។

# ៣. កិច្ចបញ្ជិកាគណនេយ្យ

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវញែកដាក់ពីគ្នារវាង ដើមទុនវិនិយោគ ទ្រព្យសកម្ម ទ្រព្យអកម្ម បុគ្គលិក-កម្មករ អ្នកគ្រប់គ្រង និងព័ត៌មានហិរញ្ញវត្ថុផ្សេងៗ ដែលសម្រាប់បម្រើឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល និងដែលសម្រាប់បម្រើឱ្យសកម្មភាពអាជីវកម្មដោយឡែក។
- អ្នកជាប់ពន្ធតូច ត្រូវអនុវត្តវិធាន និងគោលការណ៍នៃបញ្ជីគណនេយ្យសាមញ្ញ
- អ្នកជាប់ពន្ធមធ្យមឬអ្នកជាប់ពន្ធធំ ត្រូវអនុវត្តវិធានគណនេយ្យតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល

# ចំណូលពន្ធដារត្រូវបានប្រើប្រាស់សម្រាប់

